ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីណែនាំ
# ស្តីពី
# ការបញ្ជាក់អត្រានុកូលដ្ឋាន និងកម្រិតភាពក្រីក្រដោយអាជ្ញាធរមូលដ្ឋាន ដើម្បីអនុវត្តកម្មវិធីសម្បទានដីសេដ្ឋកិច្ចក្នុងក្របខណ្ឌនៃការអនុវត្តនយោបាយចាស់សកម្មភាពថ្មីរបស់រាជរដ្ឋាភិបាលលើវិស័យដីធ្លី
# ឆ្នាំ ២០១២

បណ្ណាល័យច្បាប់-Law Library
(lawlibrarysite.wordpress.com)

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ**
**ក្រុមប្រឹក្សាគោលនយោបាយដីធ្លី**
លេខ០២២..សណាន/កគដ

រាជធានីភ្នំពេញ ថ្ងៃទី០២ខែសីហា ឆ្នាំ២០១២

# សេចក្តីណែនាំ
## ស្តីពី
## ការបញ្ជាក់អត្រានុកូលដ្ឋាន និងកម្រិតភាពក្រីក្រ ដោយអាជ្ញាធរមូលដ្ឋានដើម ដើម្បីអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច ក្នុងក្របខណ្ឌនៃការអនុវត្តនយោបាយចាស់សកម្មភាពថ្មីរបស់រាជរដ្ឋាភិបាលលើវិស័យដីធ្លី

ដើម្បីអនុវត្តបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១ បប ស្តីពីវិធានការពង្រឹងនិងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ចឲ្យមានប្រសិទ្ធភាព និងសេចក្តីណែនាំលេខ ០១៨ របស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១២ ឲ្យកាន់តែមានប្រសិទ្ធភាព ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី និងជាប្រធានគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ សូមធ្វើការណែនាំបន្ថែមលើការណែនាំកន្លងមក ដល់ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត និងជាប្រធានគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត ដូចតទៅ ៖

១. ចំពោះករណីប្រជាពលរដ្ឋដែលបានចាកចេញពីទីតាំងដែលធ្លាប់បានកាន់កាប់ ដោយអាជ្ញាធរស្ថាប័នមានសមត្ថកិច្ច ឬក្រុមហ៊ុនបានអនុវត្តត្រឹមត្រូវតាមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល និងនីតិវិធីច្បាប់ នោះការទាមទារឬអះអាងខាងលើពុំអាចយកមកដោះស្រាយឡើយ ។ ករណីនេះ អាជ្ញាធរខេត្តអាចអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ចជូនប្រជាពលរដ្ឋទាំងនោះ ដោយអនុវត្តតាមនីតិវិធីដូចតទៅ:

១.១.គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ដែលមានប្រជាពលរដ្ឋទាមទារឬអះអាងដីជាក់ស្តែង ត្រូវស្រង់ទិន្នន័យជាក់លាក់អំពីចំនួនប្រជាពលរដ្ឋទាំងនោះ និងបញ្ជូនបញ្ជីឈ្មោះនោះទៅខេត្តទីលំនៅដើមរបស់ពួកគាត់ (អាចជាប្រជាពលរដ្ឋនៃខេត្តកំពុងអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច ឬជាប្រជាពលរដ្ឋមកពីខេត្តផ្សេង) ដើម្បីធ្វើការផ្ទៀងផ្ទាត់ និងបញ្ជាក់នូវអត្រានុកូលដ្ឋានដើមនិងកម្រិតនៃភាពក្រីក្រ សម្រាប់ជាមូលដ្ឋានកំណត់ជាមុខសញ្ញាទទួលដីសម្បទានសង្គមកិច្ច។

១.២.ការបញ្ជាក់អំពីកម្រិតភាពក្រីក្រ ត្រូវអនុវត្តតាមស្មារតីនៃអនុក្រឹត្យលេខ២៩១ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១១ ស្តីពីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងសៀវភៅណែនាំស្តីពីនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ របស់ក្រសួងផែនការ។

១.៣.ទិន្នន័យអំពីអគ្រានុកូលដ្ឋាននិងកម្រិតភាពក្រីក្រ ដែលគណៈកម្មាធិការប្រើប្រាស់និងបែងចែកដីថ្នាក់ខេត្តនៃខេត្តដើមកំណើតបានបញ្ជាក់រួចហើយ ត្រូវបញ្ជូនតាមផ្លូវការទៅខេត្តអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច (ចំពោះករណីប្រជាពលរដ្ឋមកពីខេត្តផ្សេង)។

១.៤.គណៈកម្មាធិការប្រើប្រាស់និងបែងចែកដីថ្នាក់ខេត្ត នៃខេត្តអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច ត្រូវបញ្ជូនទិន្នន័យអំពីការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច ទៅអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការសម្បទានដីសង្គមកិច្ចថ្នាក់ជាតិ ដើម្បីសុំយោបល់អនុវត្ត។

២. តាមស្មារតីនៃសេចក្តីជូនដំណឹងលេខ ៦៦៦ សជណ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១២ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការប្រើប្រាស់និងបែងចែកដីថ្នាក់ខេត្ត ត្រូវចេញប័ណ្ណសម្បទានដីសង្គមកិច្ច (ដូចមានឧបសម្ព័ន្ធភ្ជាប់) ជូនអ្នកទទួលដីសម្បទានសង្គមកិច្ចរបស់រាជរដ្ឋាភិបាល ដើម្បីអាចយកប័ណ្ណនេះដាក់ហ៊ីប៉ូតែកឬបញ្ចាំបាន ក្នុងចន្លោះពេលអន្តរកាលដែលច្បាប់បានកំណត់លក្ខខណ្ឌកាន់កាប់ដីគ្រប់០៥(ប្រាំ)ឆ្នាំ ទើបអាចមានសិទ្ធិកម្មសិទ្ធិលើដីនោះ ។ ចំពោះអ្នកទទួលដីសម្បទានសង្គមកិច្ចដែលបានអនុវត្តត្រឹមត្រូវតាមកម្មវិធីសម្បទានដីសង្គមកិច្ចបាន ០៥ (ប្រាំ) ឆ្នាំ តាមលក្ខខណ្ឌដូចចែងក្នុងកិច្ចសន្យាសម្បទានដីសង្គមកិច្ចហើយ អ្នកទទួលដីមានសិទ្ធិកម្មសិទ្ធិលើដីនោះ និងអាចស្នើសុំប័ណ្ណកម្មសិទ្ធិបាន ។

សេចក្តីណែនាំនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី**

**អ៊ឹម ឈុនលឹម**

*ចម្លងជូន៖*
- *ក្រសួង/ស្ថាប័នជាសមាជិកក្រុមប្រឹក្សាគោលនយោបាយដីធ្លី*
- *ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី* 
  *"ដើម្បីជូនជ្រាប"*
- *គ្រប់សាលារាជធានី ខេត្ត*
- *គ្រប់អគ្គនាយកដ្ឋាននិងអង្គភាពជុំវិញក្រសួង ដ.ន.ស.*
- *គ្រប់មន្ទីរ ដ.ន.ស.ស. រាជធានី ខេត្ត* 
  *"ដើម្បីអនុវត្ត"*
- *ឯកសារ កាលប្បវត្តិ*

**ឧបសម្ព័ន្ធ**
*នៃសេចក្ដីណែនាំលេខ០២២ សណន/កគដ*
*ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០១២*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ប័ណ្ណសម្បទានដីសង្គមកិច្ច

**លេខ: ....................**

**ខេត្ត :** ....................
**ស្រុក :** ....................
**ឃុំ :** ..................
**ភូមិ :** ..................

**សន្លឹកផែនទីលេខ :** ......................
**ក្បាលដីលេខ :** (*ឧទាហរណ៍*00២)
**ទំហំ :** ......................
**ប្រភេទដី :** ដីកសិកម្ម និង/ឬ ដីលំនៅឋាន
**លក្ខណៈនៃការប្រើប្រាស់ដី :** ជាដីសម្បទានសង្គមកិច្ច




*យោង:*
*កិច្ចសន្យាសម្បទានដីសង្គមកិច្ច*
*ចុះថ្ងៃទី....... ខែ.......... ឆ្នាំ...........*

ធ្វើនៅ ....................... ថ្ងៃទី ........ ខែ....... ឆ្នាំ .........

**ប្រធានគណៈកម្មាធិការប្រើប្រាស់ និងបែងចែកដីថ្នាក់ខេត្ត**
**និងជាអភិបាលនៃគណៈអភិបាលខេត្ត............**




**មាត្រដ្ឋាន ១/២000**

**ប្រកាស :**
ប័ណ្ណនេះត្រូវភ្ជាប់ជាមួយនឹងកិច្ចសន្យាសម្បទានដីសង្គមកិច្ច ដើម្បីមានតម្លៃប្រើប្រាស់ដូចប័ណ្ណកម្មសិទ្ធិ រហូតដល់ប័ណ្ណកម្មសិទ្ធិស្ថាពរត្រូវបានចេញជូនសម្បទានិកដីសង្គមកិច្ច បន្ទាប់ពីបានបំពេញគ្រប់លក្ខខណ្ឌនៃសម្បទានដីសង្គមកិច្ច ។